រូបភាព - http://www.loverofsadness.net



# ស្នេហ៍មិនស្នេហ៍

មាត់ចង់ស្តី ថាអូនស្រី ស្នេហ៍ថ្លៃណាស់
ស្នេហ៍មិនស្នេហ៍ ព្រោះតែដឹង ថាខុសឆ្លង
ចិត្តដឹងច្បាស់ ថាស្នេហ៍នេះ មិនទំនង
តែកម្មលង ឱ្យបេះដូង រងទុក្ខា។

មាត់ធ្វើរឹង ប្រឹងចចេស ដេញបងចេញ
ស្នេហ៍មិនស្នេហ៍ ព្រោះតែដឹង គ្មានវាសនា
ចិត្តទោម្នេញ ដ្បិតស្រលាញ់ ពេញឱរា
ស្នេហ៍យ៉ាងណា បើដឹងថា គង់នឹងព្រាត់។

មាត់ប្រាប់ស្ងួន ថាអូនគ្មាន ក្តីស្នេហ៍ស្និទ្ធ
ស្នេហ៍មិនស្នេហ៍ ព្រោះតែដឹង បែកប្រាកដ
តែចិត្តពិត រឹតហាមណាស់ រឹតប្រតិព័ទ្ធ
ស៊ូខាំមាត់ ឃាត់ទឹកភ្នែក បែកវរមិត្ត។

មាត់ខំប្រាប់ ថាមិនស្តាប់ ពាក្យបងស្តី
ស្នេហ៍មិនស្នេហ៍ ព្រោះតែអូន ស្នេហ៍បងពិត
តែចិត្តស្រី សែនអាណោច ខ្លោចអាណិត
ទើបដាច់ចិត្ត ប្រតិដ្ឋពាក្យ កុហកពៅ។

មាត់ប្រាប់បង ថានួនល្អង ស្អប់បងក្រៃ
ស្នេហ៍មិនស្នេហ៍ ព្រោះដឹងស្នេហ៍ គ្មានជម្រៅ
ប្រាណស្ទើរក្ស័យ ព្រោះហរទ័យ ស្នេហ៍និត្យនៅ
ស្នេហ៍ម្តេចទៅ បើនឹងត្រូវ បែកឃ្លាតឃ្លា។

មាត់ចង់ស្តី ឱ្យប្រុសថ្លៃ បងយល់ចិត្ត
ស្នេហ៍មិនស្នេហ៍ ព្រោះតែដឹង ស្នេហ៍ពុំជា
ខ្លាចបងគិត រឹតព្យាយាម លោមពុំងា
ស៊ូថាលា ប្រសើរជាង ស្អប់គ្នាក្រោយ។

មាត់ធ្វើរឹង ប្រឹងចចេស វេសពីអ្នក
ស្នេហ៍មិនស្នេហ៍ ព្រោះដឹងស្នេហ៍ នឹងរុះរោយ
ខ្លាចបងធ្លាក់ អន្ទាក់ស្នេហ៍ មិនអាចថយ
ស៊ូបណ្តោយ ឱ្យបងទៅ ទាំងទឹកភ្នែក។

មាត់ប្រាប់ស្ងួន ថាអូនគ្មាន ចិត្តស្រណោះ
ព្រោះខ្លាចប្រុស បងមិនអាច កាត់ចិត្តបែក
ស្នេហ៍មិនស្នេហ៍ ព្រោះដឹងស្នេហ៍ គង់រហែក
ទើបស៊ូបែក ចែកមាគ៌ា គ្នាទីទៃ។

មាត់ប្រាប់ស្ងួន ឱ្យនឹមនួន បំភ្លេចខ្ញុំ
ទ្រូងអួលធំ ព្រោះស្រណោះ ប្រុសថ្លើមថ្លៃ
ស្នេហ៍មិនស្នេហ៍ ព្រោះដឹងស្នេហ៍ មិនប្រពៃ
ស្នេហ៍ធ្វើអ្វី គង់មានថ្ងៃ ជួបទុក្ខព្រួយ។

មាត់ខំប្រាប់ ថាមិនស្ដាប់ បងអង្វរ
បងធ្វើល្អ ក៏អូនធ្វើ មិនរញ្ជួយ
ស្នេហ៍មិនស្នេហ៍ ព្រោះតែដឹង ថាថ្ងៃមួយ
យើងត្រូវព្រួយ ព្រោះស្នេហ៍ព្រាត់ ភ្លាត់ចាកស្ថាន។

ស៊ូឱ្យបង ស្អប់ពុំងា គ្រានេះចុះ
ដើម្បីប្រុស បងថ្ងៃក្រោយ បានសុខសាន្ត
ស៊ូឱ្យបង យល់ថាអូន ចិត្តសាមាន្យ
ប្រសើរជាង ជួបកល្យាណ ហើយនិរាស។

ស៊ូមិនជួប ប្រសើរជាង ជួបហើយបែក
ស្នេហ៍បងពេក ទើបពុះពារ ដកកាយចៀស
ស៊ូមិនស្នេហ៍ កុំឱ្យចិត្ត ស្នេហ៍វិនាស
កាយនិរាស ប្រសើរជាង វិនាសចិត្ត។

**ម៉ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី**



រូបភាព - http://www.blogskins.com/info/104605